គណបក្សសង្គ្រោះជាតិ នៃ ទ្វីបអាមេរិកខាងជើង
Cambodia National Rescue Party of North America
សង្គ្រោះ បម្រើ ការពារ RESCUE SERVE PROTECT

# សេចក្តីថ្លែងការណ៍

**គណបក្សសង្គ្រោះជាតិទ្វីបអាមេរិកខាងជើង** មានការសោកស្តាយយ៉ាងខ្លាំងបន្ទាប់ពីបានទទួលដំណឹងថា លោក **សម រង្ស៊ី** បានលាលែងពីតួនាទីជាប្រធាន និងសមាជិកភាពរបស់ **គណបក្សសង្គ្រោះជាតិ** កាលពីពេលថ្មីៗនេះ។

យើងខ្ញុំសូមសម្តែងនូវសេចក្តីគោរពចំពោះការសម្រេចចិត្តរបស់លោក **សម រង្ស៊ី** ដែលជាស្មារតីតម្កល់នូវឧត្តមប្រយោជន៍ជាតិជាធំ និងជាគំរូនៃការដឹកនាំនៅក្នុងសង្គមប្រជាធិបតេយ្យ។

យើងខ្ញុំចងចាំជានិច្ចនៅក្នុងក្រអៅបេះដូងនូវវីរៈភាព និងគុណូបការៈដ៏ឧត្តុង្គឧត្តមរបស់លោក **សម រង្ស៊ី** ចំពោះសេចក្តីលះបង់ដ៏ធំធេង ដែលមិនអាចកាត់ថ្លៃបានក្នុងនាមជាមគ្គុទ្ទេសក៍ដ៏ឆ្នើម ដែលបានត្រួសត្រាយ និងតស៊ូយ៉ាងស្វិតស្វាញ ដើម្បីនាំយកសេរីភាព និងលទ្ធិប្រជាធិបតេយ្យពិតប្រាកដមួយជូនប្រជាជាតិខ្មែរ។

បើទោះជាសេរីភាព និងលទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជានៅទទួលរងការគំរាមកំហែងយ៉ាងណាក៏ដោយ ក៏នេះនៅតែជាការបង្ហាញឲ្យឃើញនូវជោគជ័យដ៏ត្រចះត្រចង់មួយ ដែលកើតចេញពីការដឹកនាំផ្ទាល់របស់លោក **សម រង្ស៊ី** ក្នុងអំឡុងពេលជាងពីរទសវត្សរ៍ចុងក្រោយនេះ ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើអយុត្តិធម៌ទាំងឡាយនៅក្នុងសង្គមខ្មែរ។

**គណបក្សសង្គ្រោះជាតិទ្វីបអាមេរិកខាងជើង** មានមោទនភាព និងភ័ព្វសំណាងដ៏ក្រៃលែងដែលធ្លាប់ទទួលបាននូវឱកាសធ្វើការក្រោមការដឹកនាំរបស់លោក **សម រង្ស៊ី** ហើយយើងខ្ញុំប្តេជ្ញាចិត្តយ៉ាងមុតមាំដើម្បីបន្តនូវបេសកកម្មដ៏ថ្លៃថ្លានេះ ដោយឈរលើគ្រឹះ និងថ្នាលដ៏រឹងមាំ ដើម្បីនាំមកនូវការផ្លាស់ប្តូរដ៏វិជ្ជមានមួយនៅក្នុងប្រវត្តិសាស្រ្តនាពេលអនាគត។

**គណបក្សសង្គ្រោះជាតិទ្វីបអាមេរិកខាងជើង** សូមគោរពជូនពរលោក **សម រង្ស៊ី** ទទួលបាននូវពុទ្ធពរទាំងបួនប្រការ និងដើម្បីស្ថិតនៅជានិម្មិត្តរូបដ៏រឹងមាំ អង់អាច និងយូរអង្វែងក្នុងការតស៊ូគ្រប់ជំនាន់របស់ជាតិខ្មែរ ដើម្បីសិទ្ធិ សេរីភាព និងប្រជាធិបតេយ្យពេញលេញពិតប្រាកដ។

ធ្វើនៅថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០១៧

**គណបក្សសង្គ្រោះជាតិ**
**ប្រចាំទ្វីបអាមេរិកខាងជើង**